មជ្ឈមណ្ឌលសិទ្ធិមនុស្សកម្ពុជា
Cambodian Center for Human Rights

# សេចក្តីប្រកាសព័ត៌មានរបស់ ម.ស.ម.ក
# សកម្មជនដីធ្លីចំនួន ១១ នាក់ត្រូវបានចាប់ខ្លួនក្នុងខេត្តកោះកុង ខណៈពួកគាត់មានបំណង យកញត្តិទៅដាក់នៅក្រសួងយុត្តិធម៌

**រាជធានីភ្នំពេញ ថ្ងៃទី០៣ ខែកក្កដា ឆ្នាំ២០២៣**

| | |
|---|---|
| កាលបរិច្ឆេទនៃហេតុការណ៍៖ | ថ្ងៃទី២៩-៣០ ខែមិថុនា ឆ្នាំ២០២៣ |
| ប្រភេទអ្នកការពារសិទ្ធិមនុស្ស៖ | សកម្មជនដីធ្លី |
| ទីកន្លែង៖ | ខេត្តកោះកុង |
| ប្រភេទនៃការគំរាមកំហែង៖ | សេរីភាពខាងការជួបប្រជុំ |

នៅម៉ោងប្រមាណ ១១ ព្រឹក ថ្ងៃទី២៩ ខែមិថុនា ឆ្នាំ២០២៣ នគរបាលស្រុកស្រែអំបិល ខេត្តកោះកុងបានចាប់ខ្លួនសកម្មជនដីធ្លីចំនួន ១១ នាក់ដែលជាសមាជិកសហគមន៍ ១៩៧ គ្រួសារ ១៧៥ គ្រួសារ និង ៨០ គ្រួសារ ក្នុងស្រុកស្រែអំបិល ខណៈពួកគេកំពុងធ្វើដំណើរក្នុងគោលបំណងយកញត្តិទៅដាក់នៅក្រសួងយុត្តិធម៌ស្នើសុំកិច្ចអន្តរាគមន៍ឱ្យតុលាការខេត្តកោះកុងទម្លាក់ចោលរាល់បទចោទប្រឆាំងនឹងសហគមន៍ពួកគេដោយសារតែសកម្មភាពការការពារធ្លី និងសុំឱ្យមានចំណាត់ការផ្លូវច្បាប់ចំពោះបុគ្គលដែលរំលោភសិទ្ធិរបស់ពួកគេ។ សកម្មជនទាំងនោះរួមមាន អ្នកស្រី ផាវ ញ៉ឹង អ្នកស្រី ដេត ហួរ អ្នកស្រី រ៉ឹក ស៊ឹង លោក ហេង ជ័យ លោក សុខ ជ័យ លោក ឡាំ ជាវ អ្នកស្រី សេង លីន អ្នកស្រី យឿន ខ្មៅ អ្នកស្រី យី គន្ធា អ្នកស្រី ទិន តាំង និងអ្នកស្រី សួន ថេង។ ក្មេងស្រីអាយុប្រាំពីរឆ្នាំមួយរូបត្រូវបាននាំទៅជាមួយខណៈពេលចាប់ខ្លួននោះផងដែរ។ សហគមន៍ទាំងបីខាងលើបានជួបបញ្ហាដីធ្លីតាំងពីឆ្នាំ២០០៦ មកម្ល៉េះ។

សកម្មជនមួយរូបបាននិយាយថា បន្ទាប់ពីការចាប់ខ្លួនពួកគេត្រូវបាននាំខ្លួនទៅអធិការដ្ឋាននគរបាលស្រុកស្រែអំបិលភ្លាមៗដើម្បីសួរចម្លើយ មុននឹងបញ្ជូនទៅស្នងការដ្ឋាននគរបាលខេត្តកោះកុងដើម្បីសួរចម្លើយបន្ថែមរហូតដល់ម៉ោង ១ រំលងអាធ្រាត ឈានចូលថ្ងៃទី៣០ ខែមិថុនា ឆ្នាំ២០២៣ ។ សកម្មជនមួយរូបត្រូវបានដោះលែងនៅដំណាក់កាលនគរបាល ចំណែកសកម្មជនផ្សេងត្រូវបានបញ្ជូនទៅសាលាដំបូងខេត្តកោះកុងដើម្បីបន្តនីតិវិធីនៅព្រឹកថ្ងៃទី៣០ ខែមិថុនា ឆ្នាំ២០២៣ ។ អ្នកស្រី ផាវ ញ៉ឹង អ្នកស្រី ដេត ហួរ លោក ហេង ជ័យ លោក សុខ ជ័យ លោក

ឡាំ ជាវ អ្នកស្រី សេង លីន អ្នកស្រី យឿន ខ្មៅ អ្នកស្រី យី គន្ធា អ្នកស្រី ទិន តាំង និងអ្នកស្រី សួន ថេង ត្រូវបានតុលាការចោទពីបទ «ញុះញង់ឱ្យប្រព្រឹត្តបទឧក្រិដ្ឋជាអាទិ៍» និងត្រូវបានបង្គាប់ឱ្យឃុំខ្លួនបណ្ដោះអាសន្ននៅពន្ធនាគារខេត្តកោះកុង។ ទោះបីដូច្នេះក៏ដោយ សកម្មជនម្នាក់ដែលមានកូនស្រីអាយុប្រាំពីរឆ្នាំទៅជាមួយ ត្រូវបានដោះលែងឱ្យនៅក្រៅឃុំបណ្ដោះអាសន្ន ប៉ុន្តែដាក់ឱ្យស្ថិតក្រោមការត្រួតពិនិត្យតាមផ្លូវតុលាការដោយភ្ជាប់ជាមួយនឹងលក្ខខណ្ឌដូចជា ហាមផ្លាស់ប្តូរទីលំនៅដោយគ្មានការអនុញ្ញាតពីចៅក្រមស៊ើបសួរ ត្រូវឆ្លើយតបតាមដីការកោះពីគ្រប់បុគ្គលដែលចាត់តាំងដោយចៅក្រមស៊ើបសួរ និងត្រូវបង្ហាញខ្លួននៅចំពោះមុខចៅក្រមស៊ើបសួរនៃសាលាដំបូងខេត្តកោះកុងរយៈពេលពីរខែម្តង ក្នុងករណីមិនអនុវត្តតាម គាត់អាចនឹងត្រូវចាប់ខ្លួនសារជាថ្មី។ គួរឱ្យកត់សម្គាល់ផងដែរថាកូនប្រុសរបស់អ្នកស្រី ផាវ ញ៉ឹង អាយុ ១៨ ខែម្នាក់ក៏កំពុងស្ថិតក្នុងពន្ធនាគារជាមួយអ្នកស្រី ផាង ញ៉ឹង ផងដែរ ក្រោយពីកុមារ៉ារូបនោះបានទៅតាមអ្នកស្រីនៅក្នុងដំណាក់កាលនៃនីតិវិធីនៅតុលាការកាលពីថ្ងៃទី៣០ ខែមិថុនា ឆ្នាំ ២០២៣។

នៅថ្ងៃទី០១ ខែកក្កដា ឆ្នាំ២០២៣ មន្ត្រីពន្ធនាគារខេត្តកោះកុងមិនអនុញ្ញាតឱ្យក្រុមគ្រួសារសកម្មជនកំពុងជាប់ឃុំចូលសួរសុខទុក្ខពួកគេឡើយ ដោយលើកយកហេតុផលថាកំពុងមានជំងឺឆ្លងនៅក្នុងពន្ធនាគារ។ ទោះជាយ៉ាងនេះក៏ដោយ ពួកគេត្រូវបានអនុញ្ញាតឱ្យផ្ញើអាហារដល់សាច់ញាតិរបស់ខ្លួន។

**សម្រាប់ព័ត៌មានបន្ថែម សូមទាក់ទងលោក វណ្ណ សុផាត អ្នកសម្របសម្រួលគម្រោងធុរកិច្ចនិងសិទ្ធិមនុស្ស នៃ ម .ស.ម.ក តាមរយៈទូរស័ព្ទ៖ +៨៥៥ (០) ១២ ៩៤១ ២០៦ ឬអ៊ីម៉ែល៖** vann.sophath@cchrcambodia.org